D42188





◀ សម្ដេចឪ ទ្រង់កំពុងថ្លែងព្រះរាជសាសន៍ទៅកាន់សភាទាំងពីរ

# ព្រះសារលិខិតនៃ សម្ដេចសហាជីវិន ព្រះប្រមុខរដ្ឋទ្រង់ថ្លែង ទៅកាន់សភាទាំងពីរ

ថ្ងៃទី ២៣ តុលា ១៩៦៧

នៅក្នុងព្រះសារលិខិតដែលសម្ដេចសហាជីវិនព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់ថ្លែងក្នុងឱកាសបើកសម័យប្រជុំនៃសភាទាំងពីរ នាថ្ងៃទី ២៣ តុលាមុននេះ ព្រះអង្គបានមានព្រះបន្ទូលអំពីបញ្ហាជាតិជាច្រើនដូចតទៅនេះ៖

## បញ្ហាក្នុងផ្ទៃប្រទេស
### អំពីខ្មែរក្រហមនិងខ្មែរខៀវ

«ជូចសហជីវិន - សហជីវិនី ជ្រាបស្រាប់ បញ្ហាដែលគួរឲ្យព្រួយបារម្ភជាងគេគឺបញ្ហាសំឡូត ។

«ឥឡូវនេះបញ្ហាសំឡូតនេះគឺបានស្រាយហើយ ។ ដោយសារការខ្នះខ្នែងរបស់ខ្ញុំ និងរបស់សហ.ជីវិន ជាអ្នកជាតិនិយមពិតប្រាកដដែលជួយខ្ញុំ ពួកអ្នកស្រុកដែលបានទទួលបាបគ្រោះដោយពាក្យឃោសនារបស់ខ្មែរក្រហមបានភ្ញាក់ស្មារតីថា ខ្លួនបាញ់បោកគេជាពិតប្រាកដកាលពីពេលមុន ។ ជនរួមជាតិយើងក្នុងតំបន់នោះ ទាំងប៉ុន្មានបានធ្វើសេចក្ដីសច្ចាប្រណិធានថា អំណើះតទៅ នឹងតាំងខ្លួនជាពលរដ្ឋស្មោះត្រង់បំផុត ចំពោះរាជបល្ល័ង្ក និងសង្គម ព្រមទាំងតាំងចិត្តថា នឹងពិចារណាមើលឲ្យច្បាស់លាស់សិនមុននឹងជឿតាមគេ ។ ក្នុងពេលនោះ បាននាំគ្នាមកគាល់ខ្ញុំយ៉ាងសន្ធឹកសន្ធាប់តគតទៅ ពាល់តែខ្ញុំបញ្ឈប់ជូនហើយបញ្ឈប់ទៀតថា សុំកុំឲ្យអញ្ជើញមកភ្នំពេញ ដើម្បីនឹងសំដែងនូវសេចក្ដីស្នេហាយ៉ាងខ្លាំងរបស់ខ្លួន និងសេចក្ដីស្មោះត្រង់របស់ខ្លួនចំពោះខ្ញុំទៀត ពីព្រោះការធ្វើដំណើរពីស្រុកភូមិ មកកាន់ភ្នំពេញតាំងឲ្យខាតពេលវេលានិងសោហ៊ុយច្រើនណាស់ !

«ក្នុងកម្មវិធីប៉ុន្មានខែក្រោយនេះ នៅតាមខេត្តនានាទាំងអស់ ខ្ញុំបានទទួលនូវកិត្តិនាមយ៉ាងរំភើប ហើយដ៏ច្រើនលើសលប់ សំដែងឲ្យឃើញនូវស្មារតីរបស់ប្រជាកស្ដ្រយើង ចំពោះឧត្តមគតិនៃសង្គម ។ នៅគ្រប់ទិសទីមហាជាតិយើងបានទទួលសេចក្ដីគួរអរសោទរយ៉ាងគ្រេកគ្រេកាលបំផុត ហើយខ្ញុំពុំដែលបានជួបនឹងអ្នកណាម្នាក់ ដែលប្រកែកពុំព្រមជួយការពារនូវឧត្តមគតិជាតិ និងពុំព្រមជួយស្ថាបនាប្រទេសជាតិឡើយ ។ បើដូចនេះចុះហេតុដូចម្ដេច បានជាពួកខ្មែរវង្វេងបីនីមួយក្ដាប់តូច បដិតខ្លួនឱ្យ

លទ្ធិជាតិខ្លួន និងអត្តការផ្ទៃនជាតិខ្លួន ព្រមទាំងចង់បំផ្លាញគូឯកការជាតិ ដែលនោះជាកម្លាំងធំបំផុតរបស់យើង គឺសកលលោកដឹងសាហាវនេះដល់ម្ល៉េះ ? ពីព្រោះនៅក្នុងចំណោមជនរួមជាតិយើង មានមនុស្សប្រកបដោយមហិច្ឆតាផ្ទាល់ខ្លួន ព្រមទាំងមានជំនឿស៊ប់ចំពោះមនោគមវិជ្ជាបរទេសមួយ ហើយបណ្ដោយខ្លួនឲ្យក្បត់មាតុប្រទេសរបស់ឯង ដែលខ្លួនអួតការពារថាខ្លួនស្រឡាញ់ ព្រមទាំងក្បត់ប្រជារាស្ត្រដែលខ្លួនហ៊ានអះអាងថាបំរើទៅវិញ។ អំពើអស់ទាំងនេះ បានធ្វើឲ្យខ្ញុំក្រៀមក្រំជារៀងរាល់ថ្ងៃ ខ្ញុំដែលទទួលបន្ទុកខុសត្រូវ ចំពោះកិច្ចទ្រទ្រង់ឯករាជ្យ និងសន្តិភាព នៅក្នុងផ្ទៃនៃកម្ពុជរដ្ឋ និងចំពោះសុភមង្គលរបស់ជនរួមជាតិយើងចំនួន ៦ លានកន្លះ ។

«ពួកខ្មែរក្រហម ដែលបះបោរ បន្តសកម្មភាព ធ្វើវិទ្ធង្សនារបស់ខ្លួន ឥតឈប់ឈរជាថាវរ ក្នុងចំណោមយុវជនយើង ដោយអយុត្តិធម៌យ៉ាងជាក់ស្ដែងបំផុត ។ ចំណែកខ្លួនខ្ញុំ ខ្ញុំគ្មានបំណងឲ្យពួកនេះបោកប្រាស់លើសុខចិត្ត ឬលើគំនិតឆាប់ជឿគេ របស់យុវជនទាំងនោះប្រយោជន៍ដើម្បីដឹកនាំឲ្យធ្លាក់ខ្លួន ក្នុងមាគ៌ានយោបាយ ដែលផ្ទុយនឹងផលប្រយោជន៍ របស់ប្រជារាស្ត្រអ្នកជាតិនិយមនោះ បានតាមចិត្តទេ ។ លទ្ធិកុម្មុយនិស្តដែលនាំចូលមកពីក្រៅ គ្មាននាំអ្វីដែលឲ្យបានចំរើនល្អគាស់គ្រាន់បើជាងនេះ ក្រៅពីភាពរំលាយនូវអត្តសញ្ញាណជាតិ គឺការបាត់បង់នូវឯករាជ្យជាតិតែប៉ុណ្ណោះ ។

ខ្ញុំបានបញ្ជាក់ជាច្រើនលើកច្រើនគ្រាមកហើយថា ខ្ញុំមិនមែនប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត មុនបានទទួលការពិសោធន៍នោះទេ ឲ្យតែលទ្ធិកុម្មុយនិស្តនោះមានលក្ខណៈជាអ្នកជាតិនិយម និងជាលទ្ធិលេចចេញពីទន្ទឹះរបស់ប្រជាពលរដ្ឋគេ ។ នៅហាណូយ គេកាន់លទ្ធិកុម្មុយនិស្តវៀតណាម នៅប៉េកាំង លទ្ធិកុម្មុយនិស្តចិន នៅព្យុងយ៉ាង លទ្ធិកុម្មុយនិស្តកូរ៉េ នៅឡាហាវ៉ាន លទ្ធិកុម្មុយនិស្តគុយបា ។ ឯលទ្ធិខ្មែរក្រហមចង់បង្ខំឲ្យគេញាក់ គឺលទ្ធិកុម្មុយនិស្តមិនមែនខ្មែរ ដែលនឹងនាំឲ្យប្រទេសកម្ពុជា ទទួលនូវការប្រមាថមើលងាយ ឬការចំអកឡកឡឺយយ៉ាងជូរចត់ អំពីសំណាក់នៃសកលលោកទាំងមូល ។ ក៏ប៉ុន្តែពួកខ្មែរក្រហមទាំងនោះសុខចិត្តជាសត្វសេក ដែលសូត្រនូវមេរៀនដែលខ្លួនបានទទួលយ៉ាងចាំមាត់ពីលោកគ្រូរបស់ខ្លួនមក ហើយដែលផ្គរលំដល់ការរស់កាន់មានការយុ នៃប្រទេសជាតិ និងដល់សុភមង្គលនៃប្រជាពលរដ្ឋយើងសូម្បីបន្តិចឡើយ ។

«ដូចខ្ញុំបានជំរាបរួចមកហើយ ខ្ញុំគ្មានញញើតនឹងចាត់វិធានការយ៉ាងហ្មត់ចត់ជាការចាំបាច់លើពួកបង្រ្កាបសន្តិភាពជាតិយើងនេះទេ ។ ខ្ញុំបានក្រើនរំលឹកឥតឈប់ឈរ សុំឲ្យពួកទាំងនេះ បំរើប្រជារាស្ត្រដោយពិតប្រាកដ តាមរយៈនៃសង្គមរាស្ត្រនិយម ឬបើយ៉ាងហោចណាស់កុំក្រេវក្រោះគោរពច្បាប់ជាតិទៅចុះ ។ ក៏ប៉ុន្តែពួកអកុសលទាំងនេះបានធ្វើខ្លួនឲ្យនិរាសចេញពីសហគមន៍ជាតិដោយខ្លួនឯង ហើយស្ម័គ្រចិត្តដើរតាមពួកគ្រូអាចារ្យបរទេសរបស់គេជាដាច់ខាត ។

«ហេតុនេះ សុំពួកទាំងនេះកុំឲ្យងឿងឆ្ងល់ចំពោះផលកម្មដែលខ្លួនបានទទួលឲ្យសោះ ។

«រីឯចំណែកខាងពួក» ខ្មែរសេរីវិញ ដែលបួងសួងចង់ឲ្យប្រទេសយើងក្លាយខ្លួនជាប្រទេសចំណុះរបស់សហរដ្ឋអាមេរិកនោះពួកនេះក៏គួរឲ្យយើងស្អប់ខ្ពើមដូចជាពួកខ្មែរក្រហមដែរ ។ ពួកខ្មែរសេរីនេះផ្ញើអនាគតរបស់ខ្លួនលើពួកខ្មែរសេរីក្បត់ជាតិ ដែលនឹងបានឡើងកាន់អំណាច នៅពេលណា ដែលពួកក្រោនគេនឹងបានគេជាបច្ចាមិត្តនៃយើង បានប្រកឹងឈ្នះយើង ដោយសារសហរដ្ឋអាមេរិកជួយជាកម្លាំង ។ ចំណែកឯពេលនោះ ពួកទាំងនេះគិតតែពីបន្តុះបង្អាប់ និងចាក់រុកឲ្យពួកកាសែតចក្រពត្តិនិយមបន្តុះបង្អាប់សង្គម និងសមិទ្ធិដែលសង្គមបានធ្វើឲ្យកើតឡើង ហើយនិងឃោសនាមួលបង្កាច់ខ្លួនខ្ញុំ ។ ក៏ប៉ុន្តែ ខ្ញុំសូមជំរាបដោយត្រង់ថា ពួកខ្មែរសេរីនេះ ពុំអាចធ្វើឲ្យយើងទទួលគ្រោះថ្នាក់អ្វីបានទេ ពីព្រោះក្រៅពីក្រុមដ៏តូចនៃពាណិជ្ជករ ចិត្តអាក្រក់ លោភលន់ឥតប្រមាណចេញ គ្មានអ្នកណាជឿតាមទេ ។ ម្យ៉ាងទៀត មកពីជនជាតិខ្មែរយើងជាជនជាតិប្រឆាំងនឹងអាណានិគមនិយមជាងគេបំផុត ។

«អាស្រ័យហេតុនេះ វិបត្តិនយោបាយ គ្មានជាគ្រោះថ្នាក់អ្វីបន្តិចដល់ប្រជារាស្ត្រយើងទេ ។ ប្រជារាស្ត្រយើងនៅតែស្មោះត្រង់ចំពោះរាជបល្ល័ង្កជាតិ ចំពោះព្រះពុទ្ធសាសនា ចំពោះសង្គមនិយមព្រះពុទ្ធសាសនា គឺថា ចំពោះសង្គមយើង ដូចពីពេលមុនជាដរាប ។



# ព្រះសារលិខិតនៃសម្តេចសហ

សម្តេច ឪ ទ្រង់ កំពុង ថ្លែង ព្រះរាជសាសន៍ទៅកាន់សភា ទាំង ពីរ

ប៉ុន្តែ ខ្ញុំសុំឲ្យអស់លោក សហជីវិន ជាអ្នកជាតិនិយម ប្រយ័ត្នឲ្យមែនទែន ចំពោះវិទ្ធង្សនានេះ អាច គំរាមកំហែងដល់សន្តិភាពនាផ្ទៃក្នុង ខាងនយោបាយ របស់ជាតិយើង ដែលញាំងឲ្យខ្មែរយើង បានថ្កុំថ្កើង រហូតមកដល់ពេលនេះ នៅឡើយ » ។

## បញ្ហាសេដ្ឋកិច្ចនិងសង្គមកិច្ច

« ក្នុងវិស័យ ពង្រីកសេដ្ឋកិច្ច និងសង្គមកិច្ច យើងចេះតែលូតលាស់ទៅមុខជានិច្ច ទោះបីយើង មានការលំបាក ខាងហិរញ្ញវត្ថុ ដោយ ។ ល្បឿននៃការស្ថាបនា ផ្លូវថ្នល់ សាលារៀន គិលានដ្ឋាន និងមន្ទីរពេទ្យគ្មានថយទេ គឺមាន តែលឿនថែមទៅទៀត ។ ក្នុង ពេលនេះ ខ្ញុំរង់តែពេលនឹងទទួល សេចក្តីអញ្ជើញរបស់ខេត្តនានា ទៅ សម្ពោធសមិទ្ធិផលថ្មីៗ ពុំបានអស់ទេ ។ ការនេះបញ្ជាក់ឲ្យឃើញច្បាស់ថា សង្គមមិនមែនជិតដាច់ខ្យល់ដូចពួក បន្តុះបង្អាប់យើង តិះតៀនផ្សាយ នោះ ទេ ។

« ការរៀបចំខាងផ្នែកឧស្សាហកម្ម ឲ្យមានរបៀបរៀបរយឡើង កំពុងតែប្រព្រឹត្តទៅជាលំដាប់ ។ សហគ្រាសរដ្ឋ បានទទួលការគ្រប់គ្រង កាន់តែមានរបៀបរៀបរយឡើងហើយ សង្ឃឹមថា នឹងបានចំណេញជាងពេលមុន ។ ឯខាងរោងចក្រឯកជន យើងត្រូវបោសសំអាត ពីព្រោះនៅមានរោងចក្រខ្លះ ដែលស្រូបយករូបិយប័ណ្ណ បរទេស អស់ជាច្រើន ដោយពុំសូវសមហេតុសមផល ហើយមានលក្ខណៈពុំស្របនឹងល័ក្ខខ័ណ្ឌនៃការផ្តល់ផលិតផលតាមធម្មតាផង ។ ហេតុនេះ ខ្ញុំសង្ឃឹមថា សហជីវិនសហជីវិនី អ្នកតំណាងរាស្ត្រ និងទីប្រឹក្សានៃព្រះរាជាណាចក្រ ដែលទទួលពាក្យអង្វរករពីមជ្ឈដ្ឋានសេដ្ឋកិច្ចខ្លះ សុំឲ្យធ្វើអន្តរាគមន៍ មុខជានឹងមានសេចក្តីប្រុងប្រយ័ត្នមែនទែន ជាមិនខាន ។

« ខាងវិស័យកសិកម្មវិញ គឺ ឃើញថា មានសេចក្តីកក់ក្តៅច្រើន ជាដើម ។ បើគ្មានហេតុភេទអ្វី ចម្លែកទេ យើងសង្ឃឹមថានឹងបាន ផលស្រូវច្រើនជាងពីឆ្នាំមុន ។ ក្នុង ឱកាសនេះ ខ្ញុំសូមថ្លែងនូវសេចក្តី សរសើរជាអតិបរមា ចំពោះ សហជីវិន សហជីវិនីខ្ញុំ ដែលបាន ផ្តល់នូវជំនួយផ្ទាល់ខ្លួន ដល់មណ្ឌល បោះឆ្នោតរបស់ខ្លួន ។ យើងនៅ មានកិច្ចការធ្វើជាច្រើន ដើម្បីដោះ ស្រាយនូវបញ្ហាទឹក បញ្ហាពូជស្រូវ និងបញ្ហាជី ។ អ្នកតំណាងរាស្ត្រ និងទីប្រឹក្សានៃព្រះរាជាណាចក្រ មានលទ្ធភាពនឹងជួយពង្រីកកសិកម្ម យើងបានជាពិសេស ដោយរួម រួមគំនិតពិភាក្សា ជាមួយនឹងពួករដ្ឋ-បាល និងពួកបច្ចេកទេសរ៍ ហេតុនេះ ខ្ញុំសុំឲ្យសហជីវិន-សហជីវិនី គ្រប់ រូបមេត្តាជួយរាជរដ្ឋាភិបាល និងខ្លួន ខ្ញុំក្នុងកិច្ចការជាមូលដ្ឋាននេះ គឺជួយ បង្កើតផលិតផល និងជួយឲ្យសេដ្ឋ កិច្ចជាតិមានដំណើររីកចំរើនមែនទែន ឡើង » ។

## យើងត្រូវពឹងផ្អែកតែលើខ្លួនយើង

« ពេលនេះជាងពេលណាៗ ទាំងអស់ យើងត្រូវមានករណីយកិច្ច សង្ឃឹមលើខ្លួនយើង តែមួយគត់ ប៉ុណ្ណោះ ។ ប្រជាជាតិយើងត្រូវ ដាក់ចិត្តឲ្យ នឹង កាលណាមិត្ត បរទេសគេបន្ថយជំនួយ ឬក៏ផ្តាច់ ជំនួយទាំងស្រុងរបស់គេ ដល់ ប្រទេសយើង ។ ពីព្រោះយើងមិន ត្រូវស្រឡាញ់ជំនួយទាំងនោះរហូត ដល់ទៅសុខចិត្តខូចខាតឯករាជ្យ ជាតិ និងបាត់បង់សន្តិភាពជាតិទេ ។

« ក្នុងសម័យនេះ ពួកយក្ស ដែលជានិមិត្តរូបយ៉ាងរឹងរូសនៃ មហាគមវិជ្ជាតីរ កំពុងតែតទល់គ្នា ដែលជាហេតុអាចនាំឲ្យប្រជាពល-រដ្ឋទាំងអស់ ក្នុងសកលលោកជួប អកុសលនេះវិនាសអន្តរាយបាន ។ ហេតុនេះ ការដែលពឹងលើជំនួយគេ ដោយឥតអៀនឥតខ្មាស និងប្រវាញ ប្រចង់ឲ្យយើង ចូលក្នុងបក្សពួក ខាង នេះ ឬខាងនោះជាដាច់ខាត គឺនាំឲ្យ មានវិទ្ធង្សនា និងការវិនាសអន្តរាយ ដល់ប្រទេសយើង ។ ជំនួយ បរទេស ដែលប៉ះពាល់ដល់ឯករាជ្យ ជាតិមិនមែនជាការប្រសើរទេ ទុក ណាជាជំនួយនោះ ញាំងឲ្យសេដ្ឋ-កិច្ចយើង ហាក់ដូចជារីកដុះដាល បែបណាក៏ដោយ ។ ជំនួយនោះ ត្រឡប់ទៅជាថ្នាំពុលបណ្តាលឲ្យ ស្លាប់បង់បាន កាលណាជំនួយ នេះ នាំឲ្យបាត់បង់នូវឯករាជ្យ និង សន្តិភាព ។

« តើប្រទេសថៃឡង់ដ៏ អាច ធ្វើនឹងជំនួយខាងហិរញ្ញវត្ថុ ខាង

# ...ព្រះប្រមុខរដ្ឋទ្រង់ថ្លែងទៅកាន់សភាទាំងពីរ

ថ្ងៃទី ២៣ តុលា ១៩៦៧

សេដ្ឋកិច្ចនិងយោធា ដែលសហរដ្ឋអាមេរិកបានផ្ដល់ឲ្យខ្មែរ ឥតសំចៃ បានបង្ហាញថានៅខ្មែរយើងអាចសុខចិត្តទទួលរងនូវនៃជំនួយទាំងនេះដោយការបាត់បង់ឯករាជ្យទាំងស្រុងការ ក្ដុករល្អួយដល់សង្គម និងដល់សេដ្ឋកិច្ច ដោយការកើតអសន្តិសុខនិងបញ្ហានឹងភាពវង្វេង ។ តាមការណ៍ពិត នៅគ្រប់ទីកន្លែងទាំងអស់ក្នុងលោក យើងសង្កេតឃើញនូវផល អាក្រក់នៃជំនួយបរទេសទាំងនេះ ដែលតែងតែមានចរិតអាក្រក់ជាដរាប ។ ក៏ប៉ុន្តែ គេខំបិទបាំងនូវចរិតអាក្រក់ទាំងនេះដូចជាសម្លៀក «បាន់ទុន» សេដ្ឋកិច្ចនៃក្រុងកាល់ហ៊ៀរជាដើម ។

«ពីព្រោះ ការដែលពួកអ្នកកំណាន់នៃប្រទេសអាហ្វ្រិក-អាស៊ី និងឡាទីន អាមេរិកមកប្រជុំគ្នា ហើយអង្វរគេសុំឲ្យពួកមហាអំណាចផ្ដល់នូវជំនួយទាំងសម្ភារៈ និងទាំងហិរញ្ញវត្ថុជាការគួរឲ្យអាម៉ាស់មុខណាស់ ។ ពួកមហាអំណាចជាម្ចាស់ជំនួយទាំងនោះ គេចាត់ទុកខ្លួនគេជាគ្រូ ជាតា ចាក់ទិនស៊ីជាមួយប្រទេសក្រីក្រនិងតូចអាចទេ យើងត្រូវយល់ឲ្យច្បាស់ថា ពាក្យដែលគេហៅ «ជំនួយ» ត្រូវតែសងគេវិញជាដាច់ខាត តាមរបៀបជាអកុសលណាមួយជាមិនខាន ព្រមទាំងមានការប្រាក់យ៉ាងខ្ពស់ថែមទៀតផង ...ចំណែកខាងខ្មែរយើង យើងពេញចិត្តនឹងខ្លួនយើងណាស់ យើងមិនអាចលះបង់នូវកិត្តិយសនិងសភាពថ្លៃថ្នូរបស់ជាតិយើងបានទេ ។

«ហេតុនេះ យើងត្រូវតែពឹងផ្អែកលើកម្លាំងផ្ទាល់របស់យើង លើឯកភាពជាតិយើង លើសន្តិភាព គុណសម្បត្តិជាតិយើង លើភោគទ្រព្យ និងការងារផ្ទាល់របស់យើង ដើម្បីកង្រើកកិច្ចការរបស់យើង ឲ្យបានដើរទៅមុខជានិច្ច ។ ជាការពិត យើងជាអ្នកក្រីក្រ តែប៉ុន្តែ សភាពក្រីក្រមិនដែលចប់មិនឲ្យប្រទេសជាតិចំរើនលូតលាស់បានយ៉ាងឆាប់រហ័សនោះទេ មានតែនាំឲ្យយើងបានចំរើនយ៉ាងឆាប់រហ័សទៅវិញទេ» ។

## ត្រូវនិយមផ្លូវជាតិ និងផ្លូវប្រាកដនិយម

«អាស្រ័យហេតុនេះ ខ្ញុំសូមឲ្យសភាទាំង ២ គេផ្ដោះស្រាយនូវបញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់យើង តាមផ្លូវជាតិនិងផ្លូវប្រាកដនិយមទៅវិញ ។ ជាការពិតត្រូវដោះស្រាយបញ្ហានានា ឲ្យបានយ៉ាងឆាប់រហ័ស ប្រយោជន៍ដើម្បីឲ្យបានទាន់នឹងល្បឿនដែលខ្ញុំចង់ឲ្យព្រះរាជាណាចក្រពិសេសឲ្យដើរទៅមុខ ។ ក្នុងគោលបំណងនេះ ខ្ញុំសូមឲ្យសហជីវិន-សហជីវិនី ពិភាក្សាហើយអនុម័តដោយរួសរាន់ នូវសេចក្ដីព្រាងច្បាប់ស្ដីពីការបែងចែកនូវសកម្មភាពខាងសេដ្ឋកិច្ចជាផែនក ១ និងសេចក្ដីព្រាងច្បាប់ស្ដីអំពីថវិកាប្រជុំ សម្រាប់ឆ្នាំ ១៩៦៧ ។

«ក្នុងវិស័យសង្គមកិច្ច យើងបានចាត់នូវការផ្ដើមគំនិតថ្មីៗ ដែលខ្ញុំសុំឲ្យសហជីវិន-សហជីវិនី មេត្តាជួយចូលរួមបង្កើតកម្លាំងផងដែរ ។ គឺការកែប្រែប្រួលនៃការសិក្សា និងការរៀបចំសាលាឯកជន ឲ្យមានរបៀបរៀបរយឡើងវិញ ឬការប្រយុទ្ធជាថ្មីចំពោះអនក្ខរកម្ម ដែលសហជីវិន-សហជីវិនី ត្រូវជួយជាវិភាគទានឲ្យបានយ៉ាងទូលំទូលាយបំផុត ។ ឯយុវជនកសិកម្មនិយមខ្មែរយើង ក៏ចាប់មានឋាមភាពស្វាហាប់ឡើងវិញ ដល់ដាច់កល់ថ្ងៃដូចដើមវិញហើយ ។ ខ្ញុំយល់ថា សមាជិកនៃសភាទាំង ២ អាចជួយអ្នកទទួលខុសត្រូវនៅតាមខេត្តនានាបានយ៉ាងស័ក្ដិសិទ្ធិ ។

«សរុបសេចក្ដីទៅ ទោះបីយើងមានការលំបាកក្នុងបច្ចុប្បន្នកាលនេះ ទោះបីយើងនៅមានឧបសគ្គ ដែលត្រូវតតាំង និងមានបញ្ហាដែលត្រូវដោះស្រាយថែមទៀតក៏ដោយ ក៏យើងអាចមានសេចក្ដីកក់ក្ដៅចំពោះអនាគតធំធេងរបស់យើងបាន ឲ្យតែយើងមានគតិបណ្ឌិត និងកម្លាំងខ្លួនឯងនឹងតាំងខ្លួនយើងឲ្យនៅជាប់ហ្វាយលើកិសនារបស់ខ្លួនយើងបាន គឺជាបើយើងនៅតែកាន់ខ្លួនយើង ជាអ្នកជាតិនិយមយ៉ាងក្លៀវក្លាដដែល» ។

## ការប្រស្រ័យទាក់ទងរវាងយើងនិងបរទេស

### កកល្អក់ក្នុងការទាក់ទងជាមួយនឹងចិន

«ជូនសហជីវិន-សហជីវិនី ជ្រាបស្រាប់ ការប្រស្រ័យទាក់ទង



# ព្រះសារលិខិតនៃសម្ដេចសហា

សម្ដេច ឪ ទ្រង់កំពុងថ្លែង ព្រះរាជសាសន៍ទៅកាន់សភា ទាំងពីរ

រវាងយើងនឹងប្រទេសចិន បានទទួលការកោតស្ញប់ បណ្ដាលមកអំពីការដែលគេល្បីងដឹកនាំ ការបដិវត្តន៍វប្បធម៌ ឲ្យចូលមកក្នុងប្រទេសយើង ។ ខ្ញុំត្រូវតែទប់ទល់នឹងការបញ្ចូលនូវមនោគមវិជ្ជានេះ ដែលជាកិច្ចគំរាមកំហែង ដល់ស្វ័យភាពនិងសន្តិភាពខាងក្នុងនៃប្រទេសយើង ហើយរឹតជាការប្រយ័ត្នទាក់ទងខ្មែរ-ចិនត្រូវយកគោលការណ៍បាន់-ឌុង ជាមូលដ្ឋានតែប៉ុណ្ណោះ មិនត្រូវយកគោលការណ៍ផ្សេងទៀតមកលាយឡំជាដាច់ខាត ។ យើងបានរះរកផ្លូវស្រោចស្រង់មិត្តភាពយើង ជាមួយនឹងប្រទេសចិន ហើយខ្ញុំស្មានមើលទៅ ប្រហែលជាប៉េកាំងយល់រឿងនេះដែរ ជាប្រទេសកម្ពុជាបានសម្រេចចិត្តជាដាច់ខាត ថានឹងតម្កល់អព្យាក្រឹតរបស់ខ្លួន និងអត្ត-សញ្ញាណបណ្ណរបស់ខ្លួនជាខ្មែរជាដាច់ខាត » ។

## វ៉ាស៊ីនតោន ត្រូវបំពេញល័ក្ខ-ខ័ណ្ឌដែលយើងបានកំណត់

« មានពួក «ខ្មែរខៀវ» ខ្លះ ហើយជាពិសេស ពួកមជ្ឈដ្ឋានបរទេសខាងលោក «សេរី» ខ្លះនៃកម្ពុជរដ្ឋ បានប្រកាសជាទ្យាកថា សីហនុ ទើបតែនឹងភ្ញាក់ខ្លួនបើកភ្នែកយ៉ាងធំៗ ហើយមុខជានឹងងាកមកស្រលាញ់អាមេរិកាំងវិញហើយ ។ ក្នុងរឿងនេះ សុំអ្នកទាំងនោះកុំច្រឡំឲ្យសោះ ។ យើងដាច់ខាតជាមិនធ្វើជាអ្នកសមគំនិត ឬជាបាវព្រាវរបស់សហរដ្ឋអាមេរិកជាពិតប្រាកដ ។ ប្រទេសកម្ពុជា មិនមែនជាប្រទេសយៀកណាមរបស់ ង្វៀន កាវគី ឬប្រទេសថៃឡង់ដ៍របស់ ថនុម គិត្តិ-ខចរ ។ ដរាបណា វ៉ាស៊ីនតោនមិនបានបំពេញនូវល័ក្ខខ័ណ្ឌដែលខ្ញុំបានកំណត់ជូនមកហើយ ដរាបនោះការប្រស្រ័យទាក់ទងជាធម្មតា រវាងយើងនឹងអាមេរិកាំង គ្មានផ្លូវនឹងធ្វើឲ្យកើតមានឡើងវិញបានឡើយ ។»

## នយោបាយបដិការ

«ការប្រស្រ័យទាក់ទងរបស់យើងជាមួយនឹងបរទេស និងតាំងលើនយោបាយបដិការជានិច្ច គឺយើងធ្វើមិត្តជាមួយប្រទេសទាំងឡាយណាដែលយកយើងជាមិត្ត យើងជាសត្រូវជាមួយនឹងប្រទេសណាដែលយកយើងជាសត្រូវ ។ ប្រទេសទាំងឡាយណាដែលគោរពឯករាជ្យនិងអព្យាក្រឹត្យយើង ហើយទទួលស្គាល់បូរណភាពនៃដែនដីយើងក្នុងបរិវេណនៃព្រំប្រទល់សព្វថ្ងៃ យើងចាត់ទុកប្រទេសនោះ ជាមិត្តនឹងយើង ។ ប្រទេសដទៃទៀតក្រៅអំពីនេះ យើងមិនត្រូវការទេ ។ ក្នុងរឿងនេះ សេចក្ដីថ្លែងការណ៍ទទួលស្គាល់ មិនទទួលស្គាល់ ឬមិនច្បាស់លាស់របស់រដ្ឋាភិបាលនានាលើព្រំប្រទល់នៃដែនដីយើង ក្នុងបច្ចុប្បន្នកាលជាវិញ្ញាសាមួយដ៏មានសារសំខាន់ ។ ក៏ប៉ុន្តែមកទល់នឹងពេលនេះ សេចក្ដីថ្លែងការណ៍ដែលយើងបានទទួល ទាំងប៉ុន្មានសុទ្ធសឹងជាកិច្ចធានាអះអាង ដល់បច្ចុប្បន្នកាលនិងអនាគតកាលរបស់យើងទល់នឹងនយោបាយពង្រីកទឹកដី ដោយអាវុធរបស់អ្នកជិតខាងយើង ។»

## ជោគជ័យថ្មីៗនៃការទូតយើង

«ក្នុងរឿងនេះ ជោគជ័យថ្មីៗរបស់យើងខាងការទូត មានសភាពគួរឲ្យកក់ក្ដៅជាពន់ពេកណាស់ ។ នៅចុងកក្កដា យើងរកបាននូវមិត្តថ្មីទៀត គឺប្រទេសម៉ូរីតានី ប្រទេសហ្គីណេនិងប្រទេសសេណេហ្គាល់ ដែលទើបនឹងទទួលស្គាល់ព្រំប្រទល់ដែនដីយើងសព្វថ្ងៃ ហើយថែមទាំងស្នើសុំប្ដូរឯកអគ្គរដ្ឋទូតជាមួយនឹងយើងទៀត ។ រីឯមិត្តអាហ្វ្រិកាំងយើងដ៏ចាស់ គឺសាធារណរដ្ឋកាប៉ូម និងប្រទេសអាល់ហ្សេរី ប្រទេសទាំងនេះបានផ្ដល់ដល់យើង នូវជំនួយយ៉ាងគាប់ប្រសើរបំផុត គឺបានទ្រទ្រង់យើងយ៉ាងច្បាស់លាស់ទល់នឹងបំណងកាត់ទឹកដីរបស់របប គ្រប់គ្រងនៃព្រៃ-នគរនិងបាងកក ។ មួយវិញទៀត សហភាពសូវៀតក៏បានទទួលគោរព ទាំងស្រុងចំពោះព្រំប្រទល់យើងសព្វថ្ងៃព្រមទាំងទទួលស្គាល់នូវសភាពជាស្ថាពរនៃព្រំប្រទល់នេះ មិនត្រូវអ្នកណាមកប៉ះពាល់បានឡើយ ។ ម្យ៉ាងទៀតខ្ញុំទើបនឹងបានទទួលពីប្រទេសហ្វីលីពីន ដែលជាប្រទេសចូលខាងអាមេរិកាំង នូវសេចក្ដីថ្លែងការណ៍ទទួលគោរពនិងទទួលស្គាល់ចំពោះបូរណភាពទឹកដីក្នុងបរិវេណនៃព្រំប្រទល់ដែនខ្មែរយើងសព្វថ្ងៃ » ។

## ផែនការថ្មីនៃពួកអាមេរិកាំង

«ហេតុនេះ ឃើញថា ទោះមិនជាមានការបង្ខិតបង្ខំរបស់ពួកចក្រ-ពត្តិនិយមបែបណាក៏ដោយ ក៏កិច្ចប្រឹងប្រែងរបស់យើង ដើម្បីតទល់នឹងបំណងកាត់ទឹកដីរបស់អ្នកនៅជិត

# [...]ព្រះប្រមុខរដ្ឋទ្រង់ថ្លែងទៅកាន់សភាទាំងពីរ

ថ្ងៃទី ២១ តុលា ១៩៦៧

ខាងយើងនៅតែបានទទួលជោគជ័យជានិច្ច ក្នុងបច្ចុប្បន្នកាល និងអនាគតកាល ។ ពួកអាមេរិកាំងដឹងខ្លួនច្បាស់អំពីបរាជ័យដែលពួកគេទើបនឹងបានទទួល ហើយបើយោលទៅតាមសារគតិមានរបស់គេ ឃើញថា មានផែនការថ្មីយកមកជំនួសផែនការចាស់គឺផែនការសម្រាប់បំរើប្រយោជន៍របស់ប្រទេសថៃឡង់ដ៍និងយៀកណាមខាងត្បូង ជាពោលរបស់គេ ។ ផែនការនេះមានសេចក្ដីស្នើសុំឲ្យប្រទេសកម្ពុជាចូលរួម ក្នុងសន្និសីទមួយជាមួយនឹងអ្នកតំណាងក្រុងបាងកក និង ព្រៃនគរ ដើម្បីសម្រុះសម្រួលអំពីបញ្ហាព្រំប្រទល់ដែនយើងដែលគេថា មានលក្ខណៈ «មិនជាក់លាក់» ។ សន្និសីទនេះនឹងរាលដាល ចេញពីគម្រោងដើម ហើយ គេចង់ឲ្យមានការអញ្ជើញសហរដ្ឋអាមេរិក សហភាពសូវៀត និងប្រទេសចិនឲ្យចូលមករួមប្រជុំផង ដើម្បីសម្រុះសម្រួលអំពីកសា របស់យៀកណាម ។

«ចម្លើយរបស់ប្រទេសកម្ពុជាចំពោះកលឧបាយរបស់អាមេរិកាំងនេះគឺការពុំព្រមទទួលស្គាល់ជាដាច់ខាត ។ ព្រំប្រទល់ដែនយើងសព្វថ្ងៃមានសភាពជាក់លាក់បំផុត ហើយមានជាងគេទទួលស្គាល់ថែមទៀតផង ។ ទោះជាការលើសលប់បែបណាក៏ដោយ គឺយើងមិនយល់ព្រមឲ្យគេលើកយកមកជជែកវែកញែកទៀតទេ ។ ការដែលនឹងឃើញថាឲ្យមានកិច្ចចរចា ឬកិច្ចសន្ទនាលើបញ្ហានេះ ដែលបានទទួលការកាត់ស្រេចបាច់រួចហើយនោះ ជាការគួរឲ្យអស់សំណើចណាស់ ។ រីឯសេចក្ដីស្នើសុំឲ្យមានការសម្រុះសម្រួលរឿងយៀកណាមដោយពួកមហាអំណាចវិញ ប្រទេសកម្ពុជាដោយគោរពតាមគោលការណ៍របស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន និង ជំទាស់ជាដាច់ខាត ហើយមុខជានឹងគាំទ្រជានិច្ចហើយ យ៉ាងហ្មឺងម៉ត់បំផុតផង ចំពោះទស្សនប្រយោជន៍នៃប្រជាជាតិយៀកណាមដែលទទួលការឈ្លានពានយ៉ាងអយុត្តិធម៌ ហើយដែលត្រូវកងកំឡាំងអាមេរិកាំងនិងពួកស៊ីឈ្នួលកំដណ្ដើមយកទឹកដីតាំងគម្រោល» ។

## អរិយាបថរបស់រណសិរ្សនិងរបស់យៀកណាមខាងជើង មានសភាពត្រឹមត្រូវណាស់

«អរិយាបថរបស់រណសិរ្សរំដោះជាតិយៀកណាមខាងត្បូង និងសាធារណរដ្ឋប្រជាធិបតេយ្យយៀកណាមខាងជើង មានសភាពត្រឹមត្រូវណាស់ ពួកអ្នកឈ្លានពានត្រូវតែដកខ្លួនចេញពីយៀក-ណាមដោយគ្មានលក្ខខ័ណ្ឌអ្វីផល់បន្តិច ហើយត្រូវតែទុកឲ្យជនជាតិយៀកណាម ដោះស្រាយកិច្ចការផ្ទាល់របស់គេដោយខ្លួនឯងផ្ទាល់ ។

«យើងមិនទទួលយល់ព្រមឲ្យមហាអំណាចបរទេសណាមួយ ឬច្រើនគ្នា មានសិទ្ធិចូលមកបំផ្លាញឯករាជ្យពេញបរិបូណ៌របស់ប្រទេសមួយទៀតទេ ។

«ពួកចក្រពត្តិនិយមអាមេរិកាំងនិងពួកអ្នកសមគំនិតរបស់គេ នៅតែបន្តនូវការឃោសនាបោទប្រកាន់លើប្រទេសកម្ពុជា ហើយនៅតែចង់ចូលមកកកក្បាលយើងជានិច្ច ។ ជារៀងរាល់ថ្ងៃ នៅតាមទល់ដែនកងទ័ពជាទាហានរបស់យើងត្រូវរុញច្រាន ពួកខ្មាំងដែលស្លាប់ស្ទ សមត្ថភាពនិងសន្ទុះចិត្តតទល់របស់យើង ។ យើងទទួលនូវការបាត់បង់ជីវិតមនុស្ស និងការបំផ្លិចបំផ្លាញអគារ ក៏ប៉ុន្តែពួកបច្ចាមិត្រនៃយើងនេះត្រូវជឿឲ្យច្បាស់ថា យើងមិនបណ្ដោយឲ្យគេធ្វើតាមចិត្តបានជាដាច់ខាត ។

«សរុបសេចក្ដីទៅ ពួកមហាអំណាចនៃបរទេសខ្លះ ទទូចគិះដៀលមួលបង្កាច់ប្រមាថមើលងាយកម្ពុជរដ្ឋយើង ។ តែកម្ពុជាយើងនៅតែមានកិត្យានុភាពនិងទទួលសេចក្ដីរាប់អានពីគ្រប់ទិសទី ក្នុងសកល-លោក កិត្យានុភាព និងសេចក្ដីរាប់អាន ដែលប្រទេសដទៃទៀតជាច្រើន ចង់បានដូចប្រទេសយើងដែរ តែធ្វើពុំកើត ។ ប្រទេសកម្ពុជានិងស្ថិតនៅក្នុងឋានៈខ្ពង់ខ្ពស់បែបនេះជានិច្ចទៅ ដរាបណាជនរួមជាតិយើងថែរក្សាឯកភាពសាមគ្គីធម៌របស់ខ្លួនបានគង់វង្ស ។ ហេតុនេះ ខ្ញុំសុំឲ្យអ្នកតំណាងរាស្ត្រនិងទីប្រឹក្សានៃព្រះរាជាណាចក្រ កុំឲ្យសំចៃកម្លាំងក្នុងការផ្គត់ផ្គង់ឯកភាពនិងសាមគ្គីនេះ នៅក្នុងផ្ទៃនៃសភាទាំង ២ និងនៅក្នុងមណ្ឌលបោះឆ្នោតរៀងៗខ្លួន» ។